*STAY AWARE OF THE FIRE DANGER RATING AND KNOW WHAT TO DO.*

# សូមយល់ដឹងអំពី FIRE DANGER RATING និងដឹងអំពីអ្វីខ្លះដែលត្រូវធ្វើ។

Fire Danger Rating ទស្សន៍ទាយថាតើភ្លើងនឹងឆេះរបៀបណានៅពេលវាចាប់ផ្តើមឆេះ, រួមមានទាំងការលំបាកនឹងពន្លត់ភ្លើងនេះផង។

កម្រិតកាន់តែខ្ពស់, លក្ខណៈកាន់តែមានគ្រោះថ្នាក់ថែមទៀត។ កម្រិតនេះគឺជាគន្លឹះរបស់លោកដើម្បីចាត់វិធានការ, ដូច្នេះហើយដើម្បីរក្សាសុវត្ថិភាពលោកអ្នកចាំបាច់យល់ដឹងអំពី Fire Danger Rating នៅក្នុងតំបន់របស់លោកអ្នក។

ក្នុងអម្លុងពេលនៃរដូវភ្លើងឆេះ, Fire Danger Rating នឹងផ្សាយនៅក្នុងការព្យាករណ៍ធាតុអាកាស, នឹងផ្សាយនៅក្នុងវិទ្យុនិងទូរទស្សន៍, ហើយនិងចេញផ្សាយក្នុងសារព័ត៌មានខ្លះៗផងដែរ។

វាក៏អាចត្រូវបានរកឃើញដែរនៅតាមវែបសៃរបស់ CFA, Department of Sustainability and Environment និង Bureau of Meteorology, ដោយទូរស័ព្ទទៅ Victorian Bushfire Information Line តាមលេខ 1800 240 667 ឬតាម National Relay Service លេខ1800 555 677។




| | តើវាមានន័យដូចម្តេចដែរ? | អ្វីខ្លះដែលខ្ញុំគួរធ្វើ? |
|---|---|---|
| **CODE RED** | › នេះគឺលក្ខណៈអាក្រក់បំផុតសំរាប ព្រៃ (bush) ឬ ភ្លើងឆេះស្មៅ (grassfire)។<br>› ផ្ទះទាំងឡាយមិនត្រូវបានគូរប្លង់ឬ សាងសង់ដើម្បីធន់នឹងភ្លើងនៅក្នុងលក្ខណៈទាំងនេះទេ។<br>› កន្លែងដែលមានសុវត្ថិភាពបំផុតគឺនៅឲ្យឆ្ងាយពីតំបន់ដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់នៃភ្លើងឆេះព្រៃ (bushfire)។ | › ការចាកចេញពីតំបន់ដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់នៃភ្លើងឆេះព្រៃ (bushfire)នៅមុន ឬពីព្រលឹមនៅថ្ងៃនោះ គឺជាជំរើសដែលមានសុវត្ថិភាពបំផុតរបស់លោកអ្នក-សូមកុំរង់ចាំមើល។<br>› សូមជៀសវាងតំបន់ដែលមានព្រៃ, គម្ពោតស្មុកឬខ្ពស់, ស្មៅស្ងួត។<br>› សូមយល់ដឹងអំពីគន្លឹះរបស់លោកអ្នក-ធ្វើការសម្រេចអំពី:<br>– ពេលណាលោកអ្នកនឹងចាកចេញ<br>– ទីកន្លែងណាដែលលោកអ្នកនឹងត្រូវទៅ<br>– តើលោកអ្នកនឹងទៅដល់ទីនោះដោយរបៀបណា<br>– ពេលណាលោកអ្នកនឹងត្រឡប់មកវិញ<br>– លោកអ្នកនឹងធ្វើអ្វីខ្លះប្រសិនបើលោកអ្នកពុំអាចចាកចេញបានទេ។ |
| **EXTREME** | › សង្ឃឹមថាលក្ខណៈក្តៅបំផុត, ស្ងួតនិងខ្យល់ខ្លាំងផង។<br>› ប្រសិនបើភ្លើងចាប់ផ្តើមហើយឆេះ, វានឹងពុំអាចទប់ទល់បាន, មិនអាចទាយទុកមុនបាននិងឆេះយ៉ាងរហ័សផង។ ភ្លើងឆេះមួយកន្លែងនឹងចាប់ផ្តើមឆេះ, រាលយ៉ាងរហ័សហើយឆេះទៅច្រើនទិស។<br>› ផ្ទះដែលមានទីតាំងមាំនិងបានសាងសង់ឬបានកែប្រែដើម្បីធន់នឹងភ្លើងឆេះព្រៃ(bushfire), ដែលបានប្រុងប្រៀបល្អនិងបានការពារយ៉ាងសកម្ម, ប្រហែលផ្តល់នូវសុវត្ថិភាព។<br>› លោកអ្នកត្រូវប្រុងប្រៀបទាំងផ្លូវកាយនិងផ្លូវចិត្តដើម្បីការពារនៅក្នុងលក្ខណៈទាំងនេះ។ | › គិតថានៅការពារផ្ទះរបស់លោកអ្នក លុះត្រាតែលោកអ្នកត្រូវបានប្រុងប្រៀបដល់កម្រិតខ្ពស់បំផុត។ នេះមានន័យ ថាផ្ទះដែលមានទីតាំងមាំនិងបានសាងសង់ឬបានកែប្រែដើម្បីធន់នឹងភ្លើងឆេះព្រៃ(bushfire), ដែលបានប្រុងប្រៀបល្អនិងលោកអ្នកអាចការពារផ្ទះយ៉ាងសកម្ម,ពេលភ្លើងចាប់ផ្តើមឆេះ។<br>› ប្រសិនបើលោកអ្នកពុំបានប្រុងប្រៀបដល់កម្រិតខ្ពស់បំផុតទេនោះ, ការចាកចេញពីតំបន់ភ្លើងឆេះព្រៃ(bushfire)ដែលមាន កម្រិតគ្រោះថ្នាក់ខ្ពស់នៅថ្ងៃនោះគឺជាជំរើសមានសុវត្ថិភាពបំផុតរបស់លោកអ្នក។<br>› ត្រូវយល់ដឹងអំពីស្ថានភាពប្រចាំតំបន់។ សូមស្វែងរកព័ត៌មានដោយស្តាប់វិទ្យុ ABC ប្រចាំតំបន់, ប៉ុស្តិ៍វិទ្យុពាណិជ្ជកម្មនិងប៉ុស្តិ៍វិទ្យុសហគមន៍ដែលត្រូវបានចាត់តាំង, ឬបើកមើលទូរទស្សន៍ Sky News TV, បើកមើលវែបសៃ **cfa.vic.gov.au**, ទូរស័ព្ទទៅកាន់ Victorian Bushfire Information Line តាមលេខ **1800 240 667** ឬតាម National Relay Service លេខ **1800 555 677**។ |
| **SEVERE** | › សង្ឃឹមថាមានលក្ខណៈក្តៅ, ស្ងួតនិងអាចមានខ្យល់ខ្លាំង។<br>› ប្រសិនបើភ្លើងចាប់ផ្តើមហើយឆេះ, វាប្រហែលជាពុំអាចទប់បានឡើយ។<br>› ផ្ទះដែលបានប្រុងប្រៀបល្អនិងបានការពារយ៉ាងសកម្មអាចផ្តល់នូវសុវត្ថិភាព។<br>› លោកអ្នកត្រូវប្រុងប្រៀបទាំងផ្លូវកាយ និងផ្លូវចិត្តដើម្បីការពារនៅក្នុងលក្ខណៈទាំងនេះ។ | › ផ្ទះប្រុងប្រៀបល្អដែលបានការពារយ៉ាងសកម្មអាចផ្តល់នូវសុវត្ថិភាព-ឆែកមើល Bushfire Survival Plan របស់លោកអ្នក។<br>› ប្រសិនបើលោកអ្នកពុំបានប្រុងប្រៀបល្អទេ, ការចាកចេញពីតំបន់ឆាប់មានភ្លើងឆេះព្រៃ(bushfire-prone)ពីព្រលឹមនៃថ្ងៃនោះគឺជាជំរើសមានសុវត្ថិភាពបំផុត។<br>› ត្រូវយល់ដឹងអំពីស្ថានភាពប្រចាំតំបន់។ សូមស្វែងរកព័ត៌មានដោយស្តាប់វិទ្យុ ABC ប្រចាំតំបន់, ប៉ុស្តិ៍វិទ្យុពាណិជ្ជកម្មនិងប៉ុស្តិ៍វិទ្យុសហគមន៍ដែលត្រូវបានចាត់តាំង, ឬបើកមើលទូរទស្សន៍ Sky News TV, បើកមើលវែបសៃ **cfa.vic.gov.au**, ទូរស័ព្ទទៅកាន់ Victorian Bushfire Information Line តាមលេខ **1800 240 667** ឬតាម National Relay Service លេខ **1800 555 677**។ |
| **VERY HIGH**<br>**HIGH**<br>**LOW-MODERATE** | › ប្រសិនបើភ្លើងចាប់ផ្តើមឆេះ, វាប្រហែលជាអាចទប់ទល់បានច្រើននៅក្នុងលក្ខណៈទាំងនេះ។<br>› គួរយល់ដឹងអំពីរបៀបដែលភ្លើងអាចចាប់ផ្តើមឆេះហើយកាត់បន្ថយគ្រោះថ្នាក់នេះ។<br>› ការដុតស្មៅដោយមានការត្រួតត្រាមើលអាចធ្វើបាននៅក្នុងលក្ខណៈទាំងនេះប្រសិនបើវាមានសុវត្ថិភាព-ឆែកមើលប្រសិនបើតម្រូវឲ្យមានច្បាប់អនុញ្ញាត។ | › ឆែកមើល Bushfire Survival Plan របស់លោកអ្នក។<br>› តាមដានមើលស្ថានភាព។<br>› ប្រហែលជាត្រូវការចាត់វិធានការ<br>› ចាកចេញប្រសិនបើចាំបាច់។ |

ចំពោះព័ត៌មានថែមទៀត: **1800 240 667** ឬ **1800 555 677** (National Relay Service) ឬ **cfa.vic.gov.au**